Columnist

នៅពេលដែលយុត្តិធម៌នៃរបបប្រល័យពូជសាសន៍ប្រឈមមុខនឹងនូវភាពអយុត្តិធម៌

•អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមកិច្ចដំណើរការរបស់តុលាការ

ដោយៈ តាំង យូ ប្រែសម្រួល ដោយញាណ សុជាតិ

នាពេលថ្មីៗកន្លងទៅនេះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានជូនដំណឹងថា ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងករណី ០០២ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមកិច្ចដំណើរការតុលាការបានទេ ដោយសារតែជនជាប់ចោទរូបនេះមានជំងឺវង្វេងវង្វាន់ស្មារតីក្នុងកម្រិតមួយដ៏ធ្ងន់ធ្ងរ ។

នៅថ្ងៃទី១៦ខែកញ្ញាឆ្នាំ២០១២នេះ ប្រធានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសម្រេចថា អៀង ធីរិទ្ធ ត្រូវដោះលែងជាមួយលក្ខខណ្ឌបណ្តោះអាសន្នមួយចំនួន ដូចជា ១)ជនជាប់ចោទត្រូវជូនដំណឹងដល់អង្គជំនុំជម្រះអំពីអាសយដ្ឋានដែលខ្លួនត្រូវបានស្នាក់នៅ ហើយមិនត្រូវផ្លាស់ប្តូរទីលំនៅដោយមិនមានការអនុញ្ញាតពីអង្គជំនុំជម្រះឡើយ ,២)ជនជាប់ចោទត្រូវប្រគល់លិខិតឆ្លងដែននិងឯកសារធ្វើដំណើរពាក់ព័ន្ធដទៃទៀត ហើយមិនត្រូវចេញក្រៅព្រំប្រទល់ដែនដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ និង ៣)ជនជាប់ចោទត្រូវគោរពតាមដីកាកោះដែលចេញដោយតុលាការ ។

ទោះបីជាមានការរំពឹងទុកបែបនេះជាយូរមកហើយយ៉ាងណាក៏ដោយ ដំណឹងអំពីការមិនមានសម្បទាគ្រប់គ្រាន់របស់ជនជាប់ចោទ និងការដោះលែងបែបនេះ នៅតែជាតថភាពមួយដែលជនរងគ្រោះនៃរបបខ្មែរក្រហមពិបាកនឹងទទួលយក។ នោះគឺជាការពិតនៅពេលដែលតួនាទីជាពិសេសរបស់អៀង ធីរិទ្ធ នៅក្នុងចលនាខ្មែរក្រហមត្រូវបានលើកមកនិយាយ ។

អៀង ធីរិទ្ធ ត្រូវបានដាក់ឈ្មោះជារឿយៗនៅក្នុងសារព័ត៌មានបរទេសថាជា 'ស្ត្រីទីមួយ' ។ ការឱ្យឈ្មោះជា 'ស្ត្រីទីមួយ' បែបនេះ គឺឋានៈមួយមិនត្រឹមត្រូវទាល់តែសោះ ហើយធ្វើឱ្យមានការយល់ខុស ។ អៀង ធីរិទ្ធ មិនមែនជាបុគ្គលមួយរូបដែលបានចូលរួមពាក់ព័ន្ធក្នុងរបបខ្មែរក្រហមដោយសារតែឋានៈរបស់ខ្លួនជាប្រពន្ធរបស់អៀង សារី និងជាប្អូនថ្លៃរបស់ ប៉ុល ពត នោះទេ ប៉ុន្តែអៀង ធីរិទ្ធ គឺជាសមាជិកបក្សកុម្មុយនិស្តកម្ពុជាដ៏មានឥទ្ធិពលមួយរូបដែលមានអំណាចទូទាំងប្រទេសក្នុងនាមជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងតួនាទីបែបនេះ អៀង ធីរិទ្ធ បាន ធ្វើកិច្ចការដោយខ្លួនឯងនិងចូលរួមពាក់ព័ន្ធដោយផ្ទាល់ក្នុងការបដិសេធផ្តល់ការព្យាបាលសុខភាពជាមូលដ្ឋានដល់ប្រជាជនកម្ពុជាគ្រប់រូបក្នុងអំឡុងពេលដែលខ្លួនកំពុងមានអំណាចនៅក្នុងរបបខ្មែរក្រហម ។ ហេតុដូច្នេះ សម្រាប់ជនរងគ្រោះការដែលអៀង ធីរិទ្ធ មានលទ្ធភាពទទួលបានការថែទាំសុខភាពលំដាប់ថ្នាក់ពិភពលោក និងទទួលបាននូវការព្យាបាលពីវេជ្ជបណ្ឌិតជំនាញជាច្រើនរូបបែបនេះ គឺជាការផ្ទុយគ្នាស្រឡះទៅនឹងអ្វីដែលអៀង ធីរិទ្ធ ធ្លាប់បានធ្វើនឹងអ្វីដែលខ្លួនធ្លាប់ហៅថា 'ការថែទាំសុខភាពប្រជាជន' នៅក្នុងរបបខ្មែរក្រហម ។

លោកស្រីអៀង ធីរិទ្ធ ក្នុងឆ្នាំ១៩៩៩ នៅប៉ៃលិន (ថតដោយលោកតាំង យូ)

បន្ថែមទៅនឹងសេវាសុខភាពយ៉ាងវិសេសវិសាលដែលអៀង ធីរិទ្ធ បានទទួលវាជាការលំបាកមួយសម្រាប់ជនរងគ្រោះ និងប្រជាជនកម្ពុជាទាំងអស់ក្នុងការទទួលយកនូវការលើកកម្ពស់សិទ្ធិរបស់ អៀង ធីរិទ្ធ ដែលកើតឡើងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សិទ្ធិការពារខ្លួនជាមូលដ្ឋាននៅតែជាទស្សនៈមួយពិបាកយល់នៅក្នុងតុលាការកម្ពុជា ។ ដូច្នេះសេចក្តីប្រកាសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអំពីសិទ្ធិទទួលបាននូវយុត្តិធម៌ និងសិទ្ធិរបស់ជនជាប់ចោទ គឺនៅតែជារឿងចម្លែក ហើយដែលគឺជាទស្សនៈរបស់បរទេសដែលបានបញ្ចូលក្នុងសង្គមប្រជាជនកម្ពុជាជាទូទៅ ។

ជាថ្មីម្តងទៀត ភាពទន់ខ្សោយនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់កម្ពុជា គឺជាកេរដំណែលនៃរបបខ្មែរក្រហមដែលបានបំផ្លិចបំផ្លាញស្ថាប័នសំខាន់ៗ និងស្ថាប័នសង្គមស៊ីវិលរបស់កម្ពុជាដែលបង្កឱ្យមានភាពអយុត្តិធម៌ដ៏ជាក់ច្បាស់នៅក្នុងស្មារតីនៃភាពអយុត្តិធម៌សម្រាប់ជនរងគ្រោះដែលមើលឃើញថា អៀង ធីរិទ្ធ បានទទួលនូវកម្រិតយុត្តិធម៌ដ៏ត្រឹមត្រូវខាងផ្លូវច្បាប់ដែលមិនមានជនជាប់ចោទកម្ពុជាណាម្នាក់អាចរំពឹងថានឹងទទួលបានដូច្នេះទេ នៅពេលប្រជាជនកម្ពុជាត្រូវបានកាត់ទោសនៅក្នុងតុលាការកម្ពុជាសូម្បីតែបទឧក្រិដ្ឋដ៏តូចតាចក៏ដោយ ។

ប្រសិនបើអៀង ធីរិទ្ធ នៅទីបំផុតអាចប្រណាំងឈ្នះនឹងពេលវេលា និងឈ្នះក្តី ដែលការទទួលខុសត្រូវរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមមិនដែលទទួលបាននូវការកាត់ទោស ហេតុការណ៍ជាអកុសលបែបនេះអាចនឹងប្រើប្រាស់ជាផ្នែកមួយនៃដំណើរការយុត្តិធម៌អន្តរកាលដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។

ទីមួយ ការមិនមានសម្បទាគ្រប់គ្រាន់និងការដោះលែងរបស់អៀង ធីរិទ្ធ មិនបង្កជាឧបសគ្គខ្លាំងដល់ដំណើរការស្វែងរកយុត្តិធម៌អន្តរកាលក្នុងកម្រិតទ្រង់ទ្រាយធំដែលកំពុងតែដំណើរការក្នុងករណី ០០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះទេ ហើយសង្ឃឹមថា នឹងបង្កើនសេចក្តីចង់បានបន្ថែមទៀតដល់តុលាការក្នុងការជំរុញកិច្ចដំណើរការទៅមុខជាបន្ទាន់ក្នុងករណីប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមដទៃទៀត ។

សេវាថែទាំសុខភាពផ្លូវចិត្តដែលអៀង ធីរិទ្ធ បានទទួល គឺជាសញ្ញាណមួយនៃសេចក្តីករុណា ប្រសិនបើប្រៀបធៀបទៅនឹងកង្វះខាតទាំងស្រុងនៃសេចក្តីករុណាបែបនេះក្នុងរបបខ្មែរក្រហម ។ ភាពពេញចិត្តមួយចំនួនអាចនឹងទទួលបានពីជនរងគ្រោះដែលត្រូវបានដកហូតឱកាសក្នុងការដាក់អៀង ធីរិទ្ធ ឱ្យទទួលខុសត្រូវតាមច្បាប់តុលាការដោយជំទាស់មិនទទួលយកបទដ្ឋានតុលាការយុត្តិធម៌ជាមូលដ្ឋានមួយ សូម្បីតែនៅចំពោះមុខឧក្រិដ្ឋកម្មដ៏ព្រៃផ្សៃដែល អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ក៏ដោយ ។ លើសពីនេះទៅទៀត បញ្ហាសុខភាពផ្លូវចិត្តដ៏ស្មុគស្មាញដែលកើតមាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចនឹងត្រូវបានយកមកប្រើប្រាស់ដើម្បីពង្រឹងវិស័យសុខភាពផ្លូវចិត្តនៅប្រទេសកម្ពុជាដែលជាកេរដំណែលនៃរបបខ្មែរក្រហម ។

ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមបានប្រើអំពើហិង្សាប្រឆាំងនឹងអារម្មណ៍ ព្រមទាំង មនោសញ្ចេតនាជាមូលដ្ឋានរបស់មនុស្ស ហើយខ្មែរក្រហមបានចាត់ទុកអាការៈនៃរោគសញ្ញាសាមញ្ញ ដូចជាឈឺក្បាលថាជាភាពទន់ខ្សោយនិងថាជាជំងឺរបស់ចក្រពត្តិនិយម ។ អ្នកដែលមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរដូចអ្វីដែលអៀង ធីរិទ្ធ កំពុងទទួលរងសព្វថ្ងៃ និងត្រូវបានកម្ចាត់ចោលភ្លាមដោយរបបខ្មែរក្រហមដែលបានចាត់ទុកថា ជាសញ្ញាណនៃភាពទន់ខ្សោយនៃសង្គមដែលត្រូវតែចាត់វិធានការ ។ នៅពេលនេះអៀង ធីរិទ្ធ ត្រូវបានផ្តល់នូវក្តីមេត្តាករុណាដែលក្តីមេត្តាករុណានេះខ្លួនបានធ្វើការយ៉ាងសកម្មដើម្បីបំបាត់ចោលក្នុងនាមជារដ្ឋមន្ត្រីខ្មែរក្រហមមួយរូប ។ ខណៈពេលដែលការធ្វើបែបនេះគឺជាទង្វើដ៏ឈឺចាប់មួយសម្រាប់ជនរងគ្រោះស្របពេលជាមួយគ្នានោះដែរ យើងក៏មានក្តីសង្ឃឹមយ៉ាងមុតមាំក្នុងផ្លូវដ៏វែងឆ្ងាយទៅមុខថាទង្វើនេះនឹងត្រូវបានមើលឃើញថា ជាភាពជោគជ័យដ៏តូចមួយសម្រាប់ភាពយុត្តិធម៌និងភាពថ្លៃថ្នូររបស់មនុស្សជាតិ ។៕ **តាំង យូ**

ទោះបីជាមានការជំទាស់តែលោកស្រីអៀង ធីរិទ្ធនៅតែត្រូវដោះលែង

ភ្នំពេញៈ លោកស្រី អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីសង្គមកិច្ច របស់តុលាការខ្មែរក្រហម កាលពីរសៀលថ្ងៃអាទិត្យ ទី១៦ ខែកញ្ញា ឆ្នាំ២០១២ ដោយភ្ជាប់ជាមួយនឹងលក្ខខណ្ឌបណ្តោះអាសន្នមួយចំនួន។

ការដោះលែងឱ្យលោកស្រី អៀង ធីរិទ្ធ ដែលមានជំងឺវង្វេងវង្វាន់ មានសេរីភាពចេញពីមន្ទីរឃុំឃាំងរបស់តុលាការខ្មែរក្រហមដូច្នេះ ត្រូវបានធ្វើឡើងតាមការសម្រេចរបស់ប្រធានអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការខ្មែរក្រហម ។

សេចក្តីប្រកាសព័ត៌មានរបស់តុលាការខ្មែរក្រហម កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២ បានបញ្ជាក់ថា ប្រធានអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការខ្មែរក្រហម ដោយអនុលោមតាមវិធាន ៨២ (៦) នៃវិធានផ្ទៃក្នុង ធ្វើការសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំផ្អាកសេចក្តីសម្រេចដោះលែងជនជាប់ចោទ អៀង-ធីរិទ្ធ ដោយគ្មានលក្ខខណ្ឌរបស់អង្គជំនុំជម្រះសាលាដំបូងដោយសម្រេចថា លោកស្រី អៀង ធីរិទ្ធ ត្រូវបានដោះលែងជាមួយលក្ខខណ្ឌបណ្តោះអាសន្នមួយចំនួនដូចជាៈ

១-ជនជាប់ចោទ ត្រូវជូនដំណឹងដល់អង្គជំនុំជម្រះអំពីអាសយដ្ឋានដែលខ្លួនត្រូវស្នាក់នៅ ហើយមិនត្រូវផ្លាស់ប្តូរទីលំនៅ ដោយមិនមានការអនុញ្ញាតពីអង្គជំនុំជម្រះឡើយ ។

២-ជនជាប់ចោទ ត្រូវប្រគល់លិខិតឆ្លងដែន និងឯកសារធ្វើដំណើរពាក់ព័ន្ធដទៃទៀត ហើយមិនត្រូវចេញក្រៅព្រំប្រទល់ដែនដី នៃព្រះរាជាណាចក្រកម្ពុជាឡើយ ។

៣-ជនជាប់ចោទ ត្រូវគោរពតាមដីកាកោះដែលចេញដោយតុលាការ ។

សេចក្តីប្រកាស ក៏បានកត់សម្គាល់ថា វិធានបណ្តោះអាសន្ននេះមានសុពលភាពរហូតដល់អង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេចទាំងស្រុងលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ។

បន្ថែមលើសេចក្តីប្រកាសពីការសម្រេចរបស់ប្រធានអង្គជំនុំជម្រះតុលាការកំពូល របស់តុលាការខ្មែរក្រហមខាងលើនេះ លោក នេត្រ ភក្ត្រា អ្នកនាំពាក្យរបស់សាលាក្តីខ្មែរក្រហម បានបញ្ជាក់ថា 'លោកស្រី អៀង ធីរិទ្ធ ត្រូវបានដោះលែង នៅម៉ោង ១ និង ៤០ នាទី (រសៀលថ្ងៃអាទិត្យ ទី១៦ ខែកញ្ញា ឆ្នាំ២០១២) ហើយការដោះលែងនេះដោយមានលក្ខខណ្ឌបណ្តោះអាសន្ន។ ការសម្រេចនោះ ដោយសារតែក្នុងរយៈពេល៤៨ ម៉ោង តាមវិធានផ្ទៃក្នុងរបស់សាលាក្តី គឺជាភារកិច្ចរបស់ប្រធានអង្គជំនុំជម្រះរបស់តុលាការកំពូល ដែលត្រូវធ្វើការសម្រេចទៅលើសំណើរបស់សហព្រះរាជអាជ្ញា ដែលបានប្តឹងសុំផ្អាកការដោះលែងបណ្តោះអាសន្ន' ។

លោក នេត្រ ភក្ត្រា បានបន្ថែមថា 'នៅក្នុងសំណើរបស់សហព្រះរាជអាជ្ញា ដែលបានប្តឹងសាទុក្ខ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ពុំបានជំទាស់ទៅនឹងការដោះលែងលោកស្រីអៀង ធីរិទ្ធទេ ប៉ុន្តែសហព្រះរាជអាជ្ញាគ្រាន់តែស្នើសុំឱ្យការដោះលែងនោះមានលក្ខខណ្ឌ ។ ដូច្នេះប្រធានអង្គជំនុំជម្រះតុលាការកំពូលរបស់សាលាក្តីខ្មែរក្រហម បានសម្រេចដោះលែងលោកស្រី អៀង ធីរិទ្ធ ដោយភ្ជាប់ជាមួយនឹងលក្ខខណ្ឌបណ្តោះអាសន្នមួយចំនួនដូចមានក្នុងសេចក្តីប្រកាសព័ត៌មាន ហើយបន្ថែមថា អង្គជំនុំជម្រះតុលាការកំពូល បង្គាប់ឱ្យលោកស្រី អៀង-ធីរិទ្ធ គោរពនូវវិធាន៣៥ ដែលទាក់ទងជាមួយនឹងការដែលមិនជ្រៀតជ្រែកទៅនឹងកិច្ចការរបស់តុលាការ ដែលនៅក្នុងនោះ មានដូចជា ការមិនឱ្យជួបពាក់ព័ន្ធជាមួយនឹងជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ព្រមទាំងជនជាប់ចោទផ្សេងទៀត លើកលែងតែលោកអៀង សារី ដែលគាត់អាចទាក់ទងបាន' ។

សូមរំលឹកថា កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការខ្មែរក្រហម បានសម្រេចជាលើកទី២ ដោះលែងលោកស្រី អៀង ធីរិទ្ធ ដោយសំអាងថា លោកស្រី ត្រូវបានអ្នកជំនាញវាយតម្លៃជាថ្មីម្តងទៀតថា លោកស្រី អៀង ធីរិទ្ធ ពិតជាមានជំងឺវង្វេងវង្វាន់ធ្ងន់ធ្ងរ និង-

តទៅទំព័រ ក3

តមកពីទំព័រ ក1

អង្គភាពអធិការ...

លើកទី១ កាលពីព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២ ដើម្បីផ្សព្វផ្សាយពីតួនាទីភារកិច្ច និងសមាសភាពរបស់អង្គភាពអធិការកិច្ចនេះ។

អនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១២ ដែលមាន១០មាត្រា បានបញ្ជាក់អំពីសមាសភាពអង្គភាពអធិការកិច្ចនេះ មានលោក ជីវ កេង សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាប្រធាន លោកចាំល់-ច័ន្ទតារា តំណាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាអនុប្រធាន លោក សេង ប៊ុនឃាង ព្រះ-រាជអាជ្ញានៃមហាអយ្យការ អមតុលាការកំពូលជាអនុប្រធាន លោកកើត រិទ្ធ អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ លោក ជ័យ សុផល ចៅក្រមតុលាការកំពូល លោក ច័ន្ទ រង្សី ចៅក្រមតុលាការកំពូល លោក ប៉ុល សំអឿន ចៅក្រមសាលាឧទ្ធរណ៍ លោកប្លង់ សំណាង ចៅក្រមសាលាឧទ្ធរណ៍ លោកហ៊ាន រិទ្ធ ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ លោក អឿង សៀង អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ លោក សេង នាង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ លោក ឧុច គីមសន ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ លោកយូ ប៊ុនណា ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ លោកស្រីចាំង ស៊ីណាត ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ លោក ហួត វុទ្ធី ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ចាម លោក កើត វណ្ណ-រ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តព្រៃវែង លោក សុខ រឿន ព្រះរាជ-អាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ លោកមាស ច័ន្ទពិសិដ្ឋ ព្រះរាជ-អាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ ជាសមាជិក អ្នកស្រីអ៊ូ រមនា ក្រឡាបញ្ជីមហាអយ្យការ អមតុលាការកំពូល កញ្ញា ហេង បូភា នាយកក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ ជាលេខាធិការ លោកអ៊ុំ វ៉ន ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ និង លោក ហេង វីរៈ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ ជាជំនួយការ ។

ក្នុងកិច្ចប្រជុំជាលើកទី១ លោក ជីវ កេង ប្រធានអង្គភាពអធិការកិច្ចបានបញ្ជាក់ថា មូលហេតុចាំបាច់ក្នុងការបង្កើតអង្គភាពនេះ គឺអនុវត្តតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី៤ ស្តីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងផែនការយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ត្រង់ចំណុចៈ ពង្រឹងការងារប្រសិទ្ធភាព និងសេរីភាពរបស់បុគ្គល ធ្វើឱ្យប្រសើរឡើងគុណភាពនៃដំណើររឿងក្តី និងសេវាពាក់ព័ន្ធ ពង្រឹងសេវាកម្ម យុត្តិធម៌ រួមមានអំណាចតុលាការនិងសេវាកម្មផ្នែកអយ្យការ ព្រមទាំងពង្រឹងស្ថាប័នវិស័យ ច្បាប់ និងតុលាការឱ្យបំពេញអាណត្តិរបស់ខ្លួនឱ្យបានសម្រេច ។

លោកជីវ កេង បានអះអាងថា ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដែលចូលជាធរមាន កាលពីខែមេសាឆ្នាំ២០១០កន្លងទៅ បានធ្វើឱ្យចៅក្រមនិងព្រះរាជអាជ្ញាខ្លះ បានត្រូវផ្តន្ទាទោស ។ ដូច្នេះការបង្កើតអង្គភាពអធិការកិច្ច គឺដើម្បីអប់រំណែនាំ ដាក់វិន័យឱ្យបានមុន ព្រមទាំងបង្ការកុំឱ្យមានបទល្មើសពិសេសចៀសវាងការទទួលទោសព្រហ្មទណ្ឌ ។ ក្នុងនោះក៏មានការលើកកម្ពស់ក្រមសីលធម៌សមត្ថភាព និងសេចក្តីថ្លៃថ្នូររបស់ចៅក្រមនិងព្រះរាជអាជ្ញាឱ្យក្លាយជាទីទុកចិត្តរបស់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន។

លោក ជីវ កេង បានបន្តថា នៅដំណាក់កាលដំបូងត្រូវបង្កើតគណៈកម្មការមួយដើម្បីរៀបចំបទបញ្ជាផ្ទៃក្នុងនៃអង្គភាពអធិការកិច្ច ហើយត្រូវចាត់តាំងក្រុមការងារជាបីក្រុម ក្នុងចំណោមសមាជិក និងមន្ត្រីជំនួយការចុះតាមខេត្ត រាជធានី ឱ្យបានមួយខែម្តង ដោយភ្ជាប់វិធីសាស្ត្រទទួល និងដោះស្រាយពាក្យបណ្តឹងនានាឱ្យបានឆាប់ ពិសេសចាត់តាំងក្រុមការងារ ចុះជាបន្ទាន់ដើម្បីរកឱ្យឃើញការពិតនិងមានដំណោះស្រាយរាល់បាតុភាពដែលកើតមាននៅតាមសាលាជម្រះក្តី ។

លោកជីវ កេងបានណែនាំក្រុមការងារនិងមន្ត្រីទាំងអស់ ដែលចុះអធិការកិច្ច ឬដោះស្រាយពាក្យបណ្តឹងឱ្យពង្រឹងគុណភាព និងភាពស្អាតស្អំ កុំឱ្យពាក់ព័ន្ធផលប្រយោជន៍ក្នុងការងារទាំងនោះ ពោលគឺការចុះធ្វើអធិការកិច្ចត្រូវប្រើប្រាស់ថវិការបស់ អង្គភាពទាំងប្រេង ការស្នាក់នៅហូបចុក និងហាមមិនឱ្យប៉ះពាល់ដល់ការចំណាយរបស់សាលាជម្រះក្តីដែលត្រូវធ្វើអធិការកិច្ចនោះទេ ប្រយោជន៍ ដើម្បីធានាភាពយុត្តិធម៌និងតម្លាភាព៕ **សារិទ្ធ**

រស្មីកម្ពុជា ប្រចាំថ្ងៃ
នាយកគ្រប់គ្រង: ផ្លូច ទុំ
និពន្ធនាយក: ម៉ែន ជេខ
អ្នកទទួលបន្ទុកការចេញផ្សាយ: នាង សារៈមុនី
លេខាធិការ: ឡាយ សុខខែត្រ
នាយផ្នែកផ្សាយពាណិជ្ជកម្ម: ឆិម លីណា
(Marketing) ទីស្នាក់ការ:
៤៧៤ មហាវិថីព្រះមុនីវង្ស ភ្នំពេញ
ការិយាល័យគ្រប់គ្រង
ទូរស័ព្ទ (០២៣) ៧២ ៦៦ ៥៥
ទូរសារ (០២៣) ២១៧១៧២
ការិយាល័យនិពន្ធ ទូរស័ព្ទ
012 990 555 / 097 33 67 666
ផ្សាយពាណិជ្ជកម្ម
(For Advertising)
Tel: (023) 72 66 55 (012) 94 90 01
(012) 99 22 22 (011) 82 35 36
(012) 97 76 88 (012) 27 55 66
(015) 92 98 98 (012) 400 022
(095) 66 16 66 (097) 72 70 709
(099) 91 92 98 (078) 76 37 64
(077) 83 77 38 (086) 23 24 26
បោះពុម្ពនៅ: ក្រុមហ៊ុន ធី ប៊ី អរ ភ្នំពេញ
T.B.R Printing Co., Ltd.
Phnom Penh, Cambodia

សេចក្តីជូនដំណឹង

ការិយាល័យនិពន្ធកាសែតរស្មីកម្ពុជារីករាយនឹងទទួលមតិយោបល់អត្ថបទនានាដែលចង់ចុះផ្សាយលើទំព័រកាសែតរស្មីកម្ពុជា ជុំវិញបញ្ហាគ្រប់វិស័យរបស់ជាតិសង្គម ។ប្រិយមិត្តអាចទាក់ទងផ្ទាល់មកទីចាត់ការរស្មីកម្ពុជាលេខ ៤៧៤, មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន (ជិតគល់ស្ពានព្រះមុនីវង្ស), ទូរស័ព្ទ:០១២ ៨៣ ៥៤ ៧៧, អ៊ីមែល rasmeikampuchea_editor@yahoo.com ៕

សេចក្តីជូនដំណឹង

កាសែតរស្មីកម្ពុជា មានកិត្តិយសជម្រាបជូនអតិថិជនដែលបានជាវកាសែតរស្មីកម្ពុជារយៈពេលមួយឆ្នាំទាំងអស់ឱ្យបានជ្រាបថា ចាប់ពីឆ្នាំ ២០០៩ នេះតទៅ អតិថិជនទាំងឡាយដែលបានជាវកាសែតរស្មីកម្ពុជារយៈ ពេលមួយឆ្នាំ យើងខ្ញុំនឹងជូនប្រអប់ដាក់កាសែតមួយដល់ទីស្នាក់ការ ឬគេហដ្ឋានផ្ទាល់ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការងារចែកផ្សាយផង និងដើម្បីចៀសវាងការបាត់បង់ឬទទឹកខូច ខាតផង ។

អាស្រ័យហេតុនេះ បើអស់លោកអ្នកមានចំណាប់អារម្មណ៍ សូមទាក់ទងទូរស័ព្ទផ្នែកចែកផ្សាយលេខ ០១៦ ៦១៦ ៨៦៩ ឬ០១១ ៣៨៧ ៨៥១ ។

បញ្ជាក់: ការចែកជូននេះធ្វើឡើងចំពោះតែអតិថិជនដែលជាវផ្ទាល់ពីផ្នែកចែកផ្សាយយើងខ្ញុំប៉ុណ្ណោះ ៕